**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :....១៧៧៧/២៣..............ក.ប/ខ.ល

## សារលិខិតជូនពរ

**សូមគោរពជូនពរ**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

***សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ ក្នុងឱកាសខួបកំណើតគម្រប់ ៤៦ ឈាន ចូល ៤៧ឆ្នាំ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** តាងនាមថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមប្រសិទ្ធពរបវរមហាប្រសើរជូនដល់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ទទួល បាននូវប្រាជ្ញាឈ្លាសវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ និងសម្រេចជោគជ័យដ៏ត្រចះត្រចង់ថ្មីបន្ថែមទៀតក្នុងគ្រប់ បេសកកម្មដ៏ឧត្តុង្គឧត្តមរបស់សម្តេចក្នុងការបម្រើប្រជាជន និងបន្តដឹកនាំប្រទេសជាតិនាំទៅរកភាពរុងរឿង និង កាន់តែរីកចម្រើនលើគ្រប់វិស័យជានិរន្តរ៍។

ជាថ្មីម្តងទៀត យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោះព្រំប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ ជូនដល់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ សូមបានសមប្រកបតែសេចក្តីសុខ និងចម្រើន ព្រមទាំងពុទ្ធពរជ័យ បួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃ អង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩